# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

របាយការណ៍ហិរញ្ញវត្ថុ

សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ

3ខែ និង 12ខែ ដែលបានបញ្ចប់

ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

និង

របាយការណ៍របស់សវនករឯករាជ្យ

ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ

សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00001157 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 212 ផ្លូវលេខ 271<br>សង្កាត់ទួលទំពូង 2<br>ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | Kookmin Bank Co., Ltd.<br>ធនាគារគូកមីន កម្ពុជា ភីអិលស៊ី | |
| ក្រុមប្រឹក្សាភិបាល | លោក JUN Kwi Sang | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក CHUNG Hui Tae | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក អ៊ុំ សមអឿន | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| | លោកបណ្ឌិត CHOI Dong Hyun | អភិបាល |
| | លោក LEE Kyung Cheon | អភិបាលឯករាជ្យ |
| | លោក PAK Jaehong | អភិបាលឯករាជ្យ |
| | លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ |
| | លោក JANG Ji Kyu | អភិបាល (លាលែងនៅថ្ងៃទី18 ខែមករា ឆ្នាំ2022) |
| គណៈកម្មាធិការប្រតិបត្តិ | លោក អ៊ុំ សមអឿន | ប្រធាននាយកប្រតិបត្តិ |
| | លោក គីម ហ្យុនជុង | អនុប្រធាននាយកប្រតិបត្តិ<br>(តែងតាំងនៅថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក ឆេ គីហ្យន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកឌីជីថល<br>(តែងតាំងនៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2022) |
| | លោក អ៊ី ជូហ្វាន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងហានិភ័យ<br>(តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| | លោក វ៉ុន ស៊ូយ៉ុន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ<br>(តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| | លោក ភោគ វណ្ណឌី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកព័ត៌មានវិទ្យា<br>(តែងតាំងនៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2022) |
| | លោក គង់ ស៊ាន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| | លោក រី វណ្ណា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងអាជីវកម្ម |
| | លោក ប៉ែន សុវណ្ណសុខស៊ីថា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ |
| | លោក ហឿន ហុន្នី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |

# ព័ត៌មានអំពីក្រុមហ៊ុន (ត)

គណៈកម្មាធិការប្រតិបត្តិ (ត)

| | | |
|---|---|---|
| | លោក ស៊ីម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ<br>(លាលែងនៅថ្ងៃទី21 ខែមករា ឆ្នាំ2022) |
| | លោក អ៊ុំ សុជន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ<br>(ចូលនិវត្តន៍នៅថ្ងៃទី24 ខែមករា ឆ្នាំ2022) |
| | លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម (លាលែងនៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ<br>(លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| | លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស<br>(លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| | លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម<br>(លាលែងនៅថ្ងៃទី26 ខែមករា ឆ្នាំ2022) |
| សវនករ | ខេភីអឹមជី ខេមបូឌា | |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 7 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ<br>របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 8 – 9 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 10 |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | 11 – 12 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 13 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 14 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 15 – 65 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សាភិបាល" ឬ "អភិបាល") នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ("ក្រុមហ៊ុន") សូមធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

នៅថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2022 ក្រុមហ៊ុនបានទទួលការយល់ព្រមជាគោលការណ៍ពី ធនាគារជាតិនៃកម្ពុជា ដើម្បីបន្តការរួមបញ្ចូលគ្នាជាមួយធនាគារគូកមីន កម្ពុជា ភីអិលស៊ី ("KBC")។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនកំពុងស្ថិតនៅក្នុងដំណាក់កាល នៃការបញ្ចប់នូវដំណើរការការរួមបញ្ចូលគ្នា និងធ្វើបច្ចុប្បន្នភាពលើអនុស្សារណៈ និងលក្ខន្តិកៈ ដើម្បីសុំការអនុម័តបន្ថែមពីក្រសួងពាណិជ្ជកម្ម។

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងទាំងនេះ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះដែរ។

## ដើមទុន

នៅថ្ងៃទី11 ខែមីនា ឆ្នាំ2022 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនរបស់ខ្លួនពី 300,000,000 ដុល្លារអាមេរិកទៅ 400,000,000 ដុល្លារអាមេរិក តាមរយៈការធ្វើមូលធនកម្មលើប្រាក់ចំណេញរក្សាទុក។ សំណើរនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី25 ខែមេសា ឆ្នាំ2022។ អនុស្សារណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ហើយទទួលបានការយល់ព្រមពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី28 ខែមេសា ឆ្នាំ2022។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានផ្តល់ដល់អតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទានអាក្រក់ដែលលុបចេញពីបញ្ជី ឬចំនួននៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថា បណ្តាទ្រព្យសកម្ម (លើកលែងបំណុល) ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង បានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងការិយបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលនៃកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមាន តួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ព្រឹត្តិការណ៍ចាប់ពីកាលបរិច្ឆេទនៃការរាយការណ៍

### (i). លក្ខខណ្ឌប្រាក់កម្ចី

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមិនបានបំពេញបាននៅលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌប្រាក់កម្ចីផ្សេងៗ ចំពោះប្រាក់កម្ចីមួយដែលមានទឹកប្រាក់យោងចំនួន 17,142,857ដុល្លារអាមេរិក និងចំពោះកិច្ចព្រមព្រៀងធានាលើមូលបត្របំណុលសម្រាប់ការធានាលើមូលបត្របំណុលត្រូវសងរបស់ខ្លួន។ នៅក្នុងកិច្ចព្រមព្រៀងបានចែងថា នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ មូលនិធិមានស្ថេរភាពដែលអាចប្រើប្រាស់បានរបស់ក្រុមហ៊ុន មិនអាចទាបជាង 85% នៃមូលនិធិមានស្ថេរភាពតាមតម្រូវការ នោះទេ បើមិនដូច្នេះទេ ប្រាក់កម្ចីនឹងត្រូវបង់តាមតម្រូវការ។ ក៏ប៉ុន្តែ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 មូលនិធិមានស្ថេរភាពដែលអាចប្រើប្រាស់បានរបស់ក្រុមហ៊ុន មានត្រឹមតែ 83.63% នៃមូលនិធិមានស្ថេរភាពតាមតម្រូវការតែប៉ុណ្ណោះ។

ក្រុមហ៊ុនបានទទួលអ៊ីម៉ែល នៅថ្ងៃទី8 ខែកុម្ភៈ ឆ្នាំ2023 និងថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2023 ពីអ្នកធានា និងម្ចាស់បំណុលរៀងគ្នា លើការអនុម័តកែប្រែលើលក្ខខណ្ឌខាងលើពី 85% មកត្រឹម80% សម្រាប់ការិយបរិច្ឆេទនៃរបាយការណ៍ដោយគិតចាប់ពីខែធ្នូ ឆ្នាំ2022 រហូតដល់ថ្ងៃទី31 ខែមីនា ឆ្នាំ2023។ ដោយផ្អែកតាមមូលដ្ឋាននៃ លក្ខខណ្ឌថ្មីនេះ រួមនឹងការព្យាករណ៍របស់ក្រុមហ៊ុន អ្នកគ្រប់គ្រងជឿថា មិនមានហានិភ័យដែលលក្ខខណ្ឌថ្មីនេះ មិនអាចបំពេញបាននោះទេ។ ក្រុមហ៊ុនកំពុងស្ថិតនៅក្នុងដំណើរការស្នើរសុំលិខិតលើកលែងលក្ខខណ្ឌប្រាក់កម្ចីជាផ្លូវការដោយយោងតាមអ៊ីម៉ែលខាងលើ។

### (ii). វិសោធនកម្មលើប្រាក់បម្រុងកាតព្វកិច្ច

បន្ទាប់មកនៅថ្ងៃទី9 ខែមករា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីប្រកាសលេខ ធ.7-023-005 អំពីការបន្ថែមអត្រាប្រាក់បម្រុងកាតព្វកិច្ចទៅជា 9% និង 12.5% សម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយប័ណ្ណ បរទេសដែលមានសុពលភាពចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2024 រៀងគ្នា។ ចំណែកឯ ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយវត្ថុជាតិ ត្រូវរក្សាអត្រានៅកម្រិត 7% ដដែល។

ក្រុមហ៊ុន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដូច្នេះប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយវត្ថុជាតិនេះ នឹងត្រូវប្តូរពី8% ទៅ7% ដោយគិតចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ជាលទ្ធផលនៃប្រកាសខាងលើ។

នៅថ្ងៃទី30 ខែមករា ឆ្នាំ2023 ក្រុមហ៊ុនបានដាក់លិខិតស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការបំពេញនូវកម្រិតប្រាក់បម្រុងកាតព្វកិច្ច ជាបួនដំណាក់កាល ដែលការទូទាត់លើកចុងក្រោយត្រឹមថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2023។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅមិនទាន់ទទួលបានការឆ្លើយតបពីធនាគារជាតិនៃកម្ពុជានៅឡើយទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក JUN Kwi Sang | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក CHUNG Hui Tae | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| លោក អ៊ុំ សមអឿន | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| លោកបណ្ឌិត CHOI Dong Hyun | អភិបាល |
| លោក LEE Kyung Cheon | អភិបាលឯករាជ្យ |
| លោក PAK Jaehong | អភិបាលឯករាជ្យ |
| លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ |
| លោក JANG Ji Kyu | អភិបាល (លាលែងនៅថ្ងៃទី18 ខែមករា ឆ្នាំ2022) |

## គណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក អ៊ុំ សមអឿន | ប្រធាននាយកប្រតិបត្តិ |
| លោក គីម ហ្យុនជុង | អនុប្រធាននាយកប្រតិបត្តិ (តែងតាំងនៅថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2022) |
| លោក ឆេ គីហ្យន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកឌីជីថល (តែងតាំងនៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2022) |
| លោក អ៊ី ជូហ្វាន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងហានិភ័យ (តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| លោក វ៉ុន ស៊ូយ៉ុន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ (តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| លោក ភោគ វណ្ណឌី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកព័ត៌មានវិទ្យា (តែងតាំងនៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2022) |
| លោក គង់ ស៊ាន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| លោក រី វណ្ណា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| លោក ប៉ែន សុវណ្ណសុខស៊ីថា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ |
| លោក ហឿន ហុន្នី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ (លាលែងនៅថ្ងៃទី21 ខែមករា ឆ្នាំ2022) |
| លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ (ចូលនិវត្តន៍នៅថ្ងៃទី24 ខែមករា ឆ្នាំ2022) |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម (លាលែងពីតំណែងថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2022) |
| លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## គណៈគ្រប់គ្រងប្រតិបត្តិ (ត)

សមាជិកគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖ (ត)

| *ឈ្មោះ* | *មុខងារ* |
| --- | --- |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម (លាលែងនៅថ្ងៃទី26 ខែមករា ឆ្នាំ2022) |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគកម្មដោយផ្ទាល់ក្នុងមូលធនរបស់ក្រុមហ៊ុនឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅ ទំព័រទី 10 ដល់ទី 65 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34")។

ក្រុមប្រឹក្សាភិបាល ត្រូវតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ ស.គ.អ.ក 34 ឬប្រសិនបើមានវៀចចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀចចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែវាមានភាពមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ (រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា) ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ថាត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

លោក JUN Kwi Sang

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 13 ខែកុម្ភៈ ឆ្នាំ2023

KPMG

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ
# របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជូនចំពោះភាគទុនិករបស់
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ដែលបានបង្ហាញនៅទំព័រទី10 ដល់ទី65 (ហៅកាត់ថា "ក្រុមហ៊ុន") ជារួមហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល") ដែលរួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022
- របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022
- របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និង
- កំណត់សម្គាល់ពន្យល់ផ្សេងៗទៀតទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

KPMG

## *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី *"ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន"*។ ការត្រួតពិនិត្យ លើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មានជាពិសេសសាកសួរបុគ្គលដែល មានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាង ការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះយើងខ្ញុំមិនបញ្ចេញមតិសវនកម្មនោះទេ។

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *("របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល")* នោះឡើយ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ព្រះរាជាណាចក្រកម្ពុជា
ខេ ភី អឹម ជី ខេមបូឌា
K P M G CAMBODIA
LTD.
ទីស្នាក់ការរាជធានីភ្នំពេញ

**ចែ៉ ហ៊ុយ**

*Senior Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 13 ខែកុម្ភៈ ឆ្នាំ 2023

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 127,423,827 | 524,603,896 | 222,365,399 | 905,916,636 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 326,284,541 | 1,343,313,455 | 368,419,366 | 1,500,940,497 |
| សមតុល្យនៅធនាគារផ្សេងៗ | 8 | 5,946,137 | 24,480,246 | 2,308,097 | 9,403,187 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 4,296,121,785 | 17,687,133,389 | 3,691,567,993 | 15,039,448,003 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 4,374,308 | 18,009,026 | 1,815,969 | 7,398,258 |
| ទ្រព្យ និងបរិក្ខារ | 11 | 4,786,735 | 19,706,988 | 4,861,518 | 19,805,825 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 12 | 18,483,310 | 76,095,787 | 16,097,643 | 65,581,798 |
| ទ្រព្យសកម្មអរូបី | 13 | 1,079,327 | 4,443,589 | 1,354,529 | 5,518,351 |
| ពន្ធពន្យារសុទ្ធជាទ្រព្យសកម្ម | 20(គ) | 14,516,880 | 59,765,995 | 11,727,635 | 47,778,385 |
| **ទ្រព្យសកម្មសរុប** | | **4,799,016,850** | **19,757,552,371** | **4,320,518,149** | **17,601,790,940** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ | 14 | 50,037,118 | 206,002,815 | 81,881,578 | 333,585,549 |
| ប្រាក់បញ្ញើរបស់អតិថិជន | 15 | 2,727,207,862 | 11,227,914,768 | 2,533,330,855 | 10,320,789,903 |
| ប្រាក់កម្ចី | 16 | 971,259,425 | 3,998,675,053 | 829,821,864 | 3,380,694,274 |
| មូលបត្របំណុលត្រូវសង | 17 | 31,168,428 | 128,320,418 | 31,342,099 | 127,687,711 |
| អនុបំណុល | 18 | 89,677,427 | 369,201,967 | 105,191,790 | 428,551,352 |
| បំណុលភតិសន្យា | 19 | 18,973,227 | 78,112,776 | 15,591,438 | 63,519,518 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20(ខ) | 41,048,919 | 168,998,400 | 34,153,679 | 139,142,088 |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 21 | 1,031,425 | 4,246,377 | 237,906 | 969,229 |
| បំណុលផ្សេងៗ | 22 | 12,998,586 | 53,515,176 | 14,627,852 | 59,593,871 |
| **បំណុលសរុប** | | **3,943,402,417** | **16,234,987,750** | **3,646,179,061** | **14,854,533,495** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 23(ក) | 400,000,000 | 1,600,000,000 | 300,000,000 | 1,200,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 423,741,506 | 1,742,202,594 | 349,600,939 | 1,430,490,098 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 23(ខ) | 31,872,927 | 129,696,057 | 24,738,149 | 100,536,219 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 50,665,970 | - | 16,231,128 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **855,614,433** | **3,522,564,621** | **674,339,088** | **2,747,257,445** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **4,799,016,850** | **19,757,552,371** | **4,320,518,149** | **17,601,790,940** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណូលការប្រាក់ | 24 | 593,225,622 | 2,424,513,117 | 505,592,378 | 2,056,749,794 |
| ចំណាយការប្រាក់ | 25 | (245,638,068) | (1,003,922,784) | (210,148,674) | (854,884,806) |
| **ចំណូលការប្រាក់សុទ្ធ** | | 347,587,554 | 1,420,590,333 | 295,443,704 | 1,201,864,988 |
| ចំណូលកម្រៃជើងសា | 26 | 9,678,144 | 39,554,575 | 8,617,690 | 35,056,763 |
| ចំណាយកម្រៃជើងសា | 26 | (1,516,730) | (6,198,876) | (118,009) | (480,061) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | 26 | 8,161,414 | 33,355,699 | 8,499,681 | 34,576,702 |
| ចំណូលផ្សេងៗ | 27 | 9,738,461 | 39,801,090 | 9,798,130 | 39,858,793 |
| ចំណូលវិភាគទាន | | 933,070 | 3,813,457 | 1,678,842 | 6,829,529 |
| ខាតសុទ្ធពីការប្តូររូបិយប័ណ្ណ | | (3,133,423) | (12,806,300) | (1,587,373) | (6,457,433) |
| **ចំណូលផ្សេងៗសរុប** | | 7,538,108 | 30,808,247 | 9,889,599 | 40,230,889 |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | 363,287,076 | 1,484,754,279 | 313,832,984 | 1,276,672,579 |
| ចំណាយលើបុគ្គលិក | 28 | (92,965,159) | (379,948,605) | (84,578,929) | (344,067,083) |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | (19,058,514) | (77,892,147) | (14,707,859) | (59,831,570) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (18,387,563) | (75,149,970) | (14,530,115) | (59,108,508) |
| រំលស់ | 30 | (6,781,962) | (27,717,879) | (6,378,059) | (25,945,944) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 226,093,878 | 924,045,678 | 193,638,022 | 787,719,474 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (44,818,533) | (183,173,344) | (38,137,058) | (155,141,552) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 181,275,345 | 740,872,334 | 155,500,964 | 632,577,922 |
| *ចំណេញលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 34,434,842 | - | 15,979,311 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 181,275,345 | 775,307,176 | 155,500,964 | 648,557,233 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណូលការប្រាក់ | 24 | 154,211,318 | 636,738,532 | 132,220,819 | 538,403,175 |
| ចំណាយការប្រាក់ | 25 | (65,098,337) | (268,791,033) | (55,720,468) | (226,893,746) |
| **ចំណូលការប្រាក់សុទ្ធ** | | 89,112,981 | 367,947,499 | 76,500,351 | 311,509,429 |
| ចំណូលកម្រៃជើងសា | 26 | 2,285,498 | 9,436,821 | 1,674,603 | 6,818,983 |
| ចំណាយកម្រៃជើងសា | 26 | (424,848) | (1,754,197) | (20,353) | (82,877) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | 26 | 1,860,650 | 7,682,624 | 1,654,250 | 6,736,106 |
| ចំណូលផ្សេងៗ | 27 | 1,547,115 | 6,388,038 | 2,135,770 | 8,696,855 |
| ចំណូលវិភាគទាន | | 394,394 | 1,628,453 | 503,203 | 2,049,043 |
| ចំណេញ/(ខាត)សុទ្ធពីការប្តូររូបិយប័ណ្ណ | | 189,504 | 782,462 | (454,593) | (1,851,103) |
| **ចំណូលផ្សេងៗសរុប** | | 2,131,013 | 8,798,953 | 2,184,380 | 8,894,795 |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | 93,104,644 | 384,429,076 | 80,338,981 | 327,140,330 |
| ចំណាយលើបុគ្គលិក | 28 | (21,341,327) | (88,118,339) | (28,216,514) | (114,897,645) |
| សំវិធានធន/(តំហាយ)លើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | (5,907,997) | (24,394,120) | 3,788,091 | 15,425,107 |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (5,238,947) | (21,631,612) | (4,359,163) | (17,750,512) |
| រំលស់ | 30 | (1,659,646) | (6,852,678) | (1,456,023) | (5,928,926) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 58,956,727 | 243,432,327 | 50,095,372 | 203,988,354 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (11,777,910) | (48,630,990) | (9,947,622) | (40,506,717) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 47,178,817 | 194,801,337 | 40,147,750 | 163,481,637 |
| *ចំណេញលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 15,294,755 | - | (3,160,776) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 47,178,817 | 210,096,092 | 40,147,750 | 160,320,861 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុង | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យថ្ងៃទី1 ខែមករា ឆ្នាំ2022 | 300,000,000 | 1,200,000,000 | 349,600,939 | 1,430,490,098 | - | - | 24,738,149 | 100,536,219 | - | 16,231,128 | 674,339,088 | 2,747,257,445 |
| មូលធនកម្មលើប្រាក់ចំណេញរក្សាទុក | 100,000,000 | 400,000,000 | (100,000,000) | (400,000,000) | - | - | - | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ | - | - | 181,275,345 | 740,872,334 | - | - | - | - | - | - | 181,275,345 | 740,872,334 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (7,134,778) | (29,159,838) | - | - | 7,134,778 | 29,159,838 | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 34,434,842 | - | 34,434,842 |
| **សមតុល្យថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | **400,000,000** | **1,600,000,000** | **423,741,506** | **1,742,202,594** | | | **31,872,927** | **129,696,057** | **-** | **50,665,970** | **855,614,433** | **3,522,564,621** |
| | | | | | | | | | | | | |
| សមតុល្យថ្ងៃទី1 ខែមករា ឆ្នាំ2021 | 230,000,000 | 920,000,000 | 285,224,840 | 1,163,897,093 | 3,151,952 | 12,773,175 | 461,332 | 1,778,127 | - | 251,817 | 518,838,124 | 2,098,700,212 |
| មូលធនកម្មលើប្រាក់ចំណេញរក្សាទុក | 70,000,000 | 280,000,000 | (70,000,000) | (280,000,000) | - | - | - | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទ | - | - | 155,500,964 | 632,577,922 | - | - | - | - | - | - | 155,500,964 | 632,577,922 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (24,276,817) | (98,758,092) | - | - | 24,276,817 | 98,758,092 | - | - | - | - |
| ការផ្ទេរពីទុនបម្រុង | - | - | 3,151,952 | 12,773,175 | (3,151,952) | (12,773,175) | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | | - | 15,979,311 | - | 15,979,311 |
| **សមតុល្យថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | **300,000,000** | **1,200,000,000** | **349,600,939** | **1,430,490,098** | **-** | **-** | **24,738,149** | **100,536,219** | **-** | **16,231,128** | **674,339,088** | **2,747,257,445** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | 31 | (278,312,753) | (1,137,464,223) | (71,081,858) | (289,161,001) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (2,042,693) | (8,348,486) | (1,282,372) | (5,216,689) |
| ការទិញទ្រព្យសកម្មអរូបី | | (16,800) | (68,662) | (43,735) | (177,914) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | (919,122) | (3,756,452) | (147,430) | (599,745) |
| សាច់ប្រាក់បានពីការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | 521,990 | 2,133,373 | 148,377 | 603,598 |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 110,688 | 452,382 | 111,776 | 454,705 |
| ការដាក់ប្រាក់តម្កល់ធានាលើដើមទុន | | (10,000,000) | (40,870,000) | (7,000,000) | (28,476,000) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (12,345,937) | (50,457,845) | (8,213,384) | (33,412,045) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 468,079,917 | 1,913,042,621 | 335,239,090 | 1,363,752,618 |
| ការទូទាត់ប្រាក់កម្ចី | | (324,659,857) | (1,326,884,836) | (295,976,678) | (1,204,033,126) |
| សាច់ប្រាក់បានពីអនុបំណុល | | - | - | 17,296,512 | 70,362,211 |
| ការទូទាត់អនុបំណុល | | (15,321,929) | (62,620,724) | (25,784,186) | (104,890,069) |
| ការទូទាត់បំណុលភតិសន្យា | | (3,973,113) | (16,238,113) | (3,618,098) | (14,718,423) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | 124,125,018 | 507,298,948 | 27,156,640 | 110,473,211 |
| **ការថយចុះសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (166,533,672) | (680,623,120) | (52,138,602) | (212,099,835) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 364,927,185 | 1,486,713,352 | 417,065,787 | 1,687,031,108 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 10,695,862 | - | 11,782,079 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 6 | 198,393,513 | 816,786,094 | 364,927,185 | 1,486,713,352 |
| **ប្រតិបត្តិការមិនមែនជាសាច់ប្រាក់ជាសារវន្តពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការបំប្លែងពីប្រាក់ចំណេញរក្សាទុកទៅដើមទុន | | 100,000,000 | 400,000,000 | 70,000,000 | 280,000,000 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នៅថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011។ ក្រុមហ៊ុនបានចុះបញ្ជីសារជាថ្មី នៅថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើនទៀតនៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2022 ក្រុមហ៊ុនបានទទួលការយល់ព្រមជាគោលការណ៍ពី ធនាគារជាតិនៃកម្ពុជា ដើម្បីបន្តការរួមបញ្ចូលគ្នាជាមួយធនាគារគូកមីន កម្ពុជា ភីអិលស៊ី("KBC")។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការបញ្ចប់នូវដំណើរការការរួមបញ្ចូលគ្នា និងធ្វើបច្ចុប្បន្នភាពលើអនុស្សរណៈ និងលក្ខន្តិកៈ ដើម្បីសុំការអនុម័តបន្ថែមពីក្រសួងពាណិជ្ជកម្ម។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមានបុគ្គលិកចំនួន 9,573នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចំនួន 9,330 នាក់)។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"* ។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុ តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ក) របាយការណ៍អនុលោមភាព (ត)

យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុន ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2023។

### (ខ) រូបិយប័ណ្ណមុខងារ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុន ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត លុះត្រាតែមានការបង្ហាញផ្សេងពីនេះ។

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មាន អថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានធ្វើតេស្តលើរំញោចនៃការផ្លាស់ប្តូរនៃប៉ារ៉ាម៉ែត្រ ដែលជាមូលដ្ឋានក្នុងការប៉ាន់ស្មាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យធ្ងន់ធ្ងរ ដែលអាចបណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ ត្រូវបានពណ៌នាដូចខាងក្រោម៖

## 2. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(i) ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូឌែលអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។

- ការកើនឡើងជាសារវន្តចំពោះហានិភ័យឥណទាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូងដែរ ឬទេ ការកំណត់វិធីសាស្ត្រសម្រាប់ការដាក់បញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត ទៅក្នុងការវាស់វែងលើ ការខាតបង់រំពឹងទុកលើឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើម៉ូឌែលសម្រាប់ការវាស់វែង ECL។

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន*

- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលធាតុចូលទៅក្នុងគំរូនៃការវាស់វែង ECL រួមទាំងការសន្មតសំខាន់ៗ ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការប៉ាន់ស្មានលើលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន និងការបញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត។

- ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយធាតុចូលមិនអាចអង្កេតបានជាសារវន្ត។

- ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗលើភវនីយភាព និងទំហំនៃលំហូរចេញនូវធនធាន។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022**

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ត) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)*

**វីរុសកូវីណា និងផលប៉ះពាល់លើ ECL**

ECL ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍នាកាលបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃវីរុសណូវែលកូរ៉ូណា ("ជំងឺកូវីដ-19") បានរាតត្បាតទូទាំងសកលលោក (រួមបញ្ចូលទាំងប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត) ដែលបានធ្វើឲ្យមានការរាំងស្ទះលើសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (GDP) និងសូចនាករសំខាន់ៗផ្សេងទៀត នឹងត្រូវយកមកពិចារណា សម្រាប់ការកំណត់នូវភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេណារីយ៉ូសេដ្ឋកិច្ចនានា ដែលត្រូវបានយកមកប្រើក្នុងការប៉ានស្មាន ECL ដែលការគណនា ECL នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនប្រាកដប្រជាជាសារវន្ត។ ការប៉ានស្មានរបស់អ្នកគ្រប់គ្រង ត្រូវបានកំណត់ដោយផ្អែកទៅលើសេណារីយ៉ូដែលអាចកើតឡើង នាពេលអនាគត ដោយគិតពីស្ថានភាពជាក់ស្តែងកាលៈទេសៈ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ច នាពេលអនាគត និងព័ត៌មានគាំទ្រដែលអាចប្រើប្រាស់បាន នាកាលបរិច្ឆេទរាយការណ៍នេះ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលត្រូវជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀលខ្មែរ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ.ក 21 – *ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស*។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022**

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល (ត)

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម នៅក្នុងការិយបរិច្ឆេទដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណ នាថ្ងៃប្រតិបត្តិការដោយសារតែអត្រាប្តូររូបិយប័ណ្ណ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាល បរិច្ឆេទរាយការណ៍ | អត្រាមធ្យម ការិយបរិច្ឆេទ 12ខែ | អត្រាមធ្យម ការិយបរិច្ឆេទ 3ខែ |
|---|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក= | 4,117 រៀល | 4,087 រៀល | 4,129 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 1 ដុល្លារអាមេរិក= | 4,074 រៀល | 4,068 រៀល | 4,072 រៀល |

ការកែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 5. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ជាទូទៅពាក់ព័ន្ធនឹងការផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗដល់ប្រជាពលរដ្ឋ សហគ្រាសធនតូច និងមធ្យម ព្រមទាំងចូលរួមក្នុងរាល់សកម្មភាពផ្សេងៗទៀត ដែលគាំទ្រដល់កម្មវត្ថុទាំងនេះ។ ពុំមានបច្ច័យដែលនាំឲ្យមានបម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម ដែលមានលក្ខណៈជាសារវន្ត ដែលពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ចទាំងនេះទេ។

## 6. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ទីស្នាក់ការកណ្តាល | 39,956,575 | 164,501,220 | 37,795,735 | 153,979,824 |
| សាខានានា | 87,467,252 | 360,102,676 | 184,569,664 | 751,936,812 |
| | 127,423,827 | 524,603,896 | 222,365,399 | 905,916,636 |

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោមៈ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សាច់ប្រាក់ក្នុងដៃ | 127,423,827 | 524,603,896 | 222,365,399 | 905,916,636 |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជា* | | | | |
| គណនីចរន្ត | 64,590,618 | 265,919,574 | 139,856,737 | 569,776,347 |
| គណនីមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | 372,869 | 1,535,102 | 373,638 | 1,522,201 |
| *សមតុល្យនៅធនាគារផ្សេងៗ* | | | | |
| គណនីចរន្ត | 2,858,502 | 11,768,453 | 2,240,993 | 9,129,805 |
| គណនីសន្សំ | 147,697 | 608,069 | 90,418 | 368,363 |
| គណនីមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | 3,000,000 | 12,351,000 | - | - |
| | 198,393,513 | 816,786,094 | 364,927,185 | 1,486,713,352 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| គណនីចរន្ត | (ក) | 64,590,618 | 265,919,574 | 139,856,737 | 569,776,347 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | (ក) | 372,869 | 1,535,102 | 373,638 | 1,522,201 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសានដំបូងច្រើនជាង 3ខែ) | (ក) | 545,316 | 2,245,066 | 148,184 | 603,702 |
| ប្រាក់តម្កល់ធានាលើដើមទុន | (ខ) | 40,000,000 | 164,680,000 | 30,000,000 | 122,220,000 |
| ប្រាក់បម្រុងកាតព្វកិច្ច | (គ) | 220,775,738 | 908,933,713 | 198,040,807 | 806,818,247 |
| | | 326,284,541 | 1,343,313,455 | 368,419,366 | 1,500,940,497 |

### (ក) គណនីចរន្ត និងប្រាក់បញ្ញើមានកាលកំណត់

គណនីចរន្តមិនទទួលបានការប្រាក់នោះទេ។

ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដំបូងរហូតដល់ 3ខែ ទទួលបាន អត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 1.54% ទៅ 3.37% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចាប់ពី 0.04% ទៅ 1.63%) ហើយប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដំបូងលើសពី 3ខែ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.83% ទៅ3.65% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចាប់ពី 0.13% ដល់ 1.91%) នៅក្នុងអំឡុងការិយបរិច្ឆេទ។

នៅក្នុងប្រាក់បញ្ញើមានកាលកំណត់ ដែលមានកាលវសានដំបូងច្រើនជាង3ខែខាងលើ បានរាប់បញ្ចូលទាំងវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន ជាមួយធនាគារជាតិនៃកម្ពុជាដែលមានចំនួន 251,000 ដុល្លារអាមេរិកដែលក្រុមហ៊ុនបានដាក់ជាវត្ថុបញ្ចាំ សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា("LPCO")។ កាលវសាននៃវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន ដែលបានដាក់ជាវត្ថុបញ្ចាំសម្រាប់LPCO មានរយៈពេល 6ខែ ដោយផ្អែកលើ កាលវសាន នៃ LPCO ហើយទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ 3.53% (2021៖ គ្មាន)។

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន

តាមប្រកាសលេខ ធ7-07-163 ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 ស្តីអំពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្រុមហ៊ុនតម្រូវឲ្យរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន (ត)

នៅថ្ងៃទី27 ខែមេសា ឆ្នាំ2022 ក្រុមហ៊ុនបានបង្កើនប្រាក់តម្កល់ធានាលើដើមទុនរហូតដល់ 40 លានដុល្លារអាមេរិក បន្ទាប់ពីទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី25 ខែមេសា ឆ្នាំ2022 លើការបង្កើនដើមទុន។ ប្រាក់បញ្ញើនេះ មិនអាចយកមកសម្រាប់ជាការប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែត្រូវបានបង្វិលត្រឡប់មកវិញ នៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ប្រាក់តម្កល់ធានាលើដើមទុន ទទួលបានការប្រាក់ប្រចាំឆ្នាំក្នុងអត្រា 1.19% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.04%) នៅក្នុងអំឡុងការិយបរិច្ឆេទ។

### (គ) ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា 8.00% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-07-163។ ប្រាក់បម្រុងកាតព្វកិច្ច នឹងត្រូវប្រែប្រួលទៅតាមកម្រិតនៃការដាក់ប្រាក់បញ្ញើពីអតិថិជន ហើយប្រាក់បម្រុងកាតព្វកិច្ចពុំទទួលបានការប្រាក់នោះទេ។

នាចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនបានរក្សានូវកម្រិតប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា នៅក្នុងគណនីបម្រុងកាតព្វកិច្ចជាមួយធនាគារជាតិនៃកម្ពុជា ស្របទៅតាមប្រកាសខាងលើ។

បន្ទាប់មកនៅថ្ងៃទី9 ខែមករា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីប្រកាសលេខ ធ.7-023-005 អំពីការបន្ថែមអត្រាប្រាក់បម្រុងកាតព្វកិច្ចទៅជា 9% និង 12.5% សម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយប័ណ្ណបរទេស ដែលមានសុពលភាពចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2024 រៀងគ្នា។ ចំណែកឯ ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយវត្ថុជាតិ ត្រូវរក្សាអត្រានៅកម្រិត 7% ដដែល។

ក្រុមហ៊ុន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដូច្នេះប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីជារូបិយវត្ថុជាតិនេះ នឹងត្រូវប្តូរពី8% ទៅ7% ដោយគិតចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023ជាលទ្ធផលនៃប្រកាសខាងលើ។

នៅថ្ងៃទី30 ខែមករា ឆ្នាំ2023 ក្រុមហ៊ុនបានដាក់លិខិតស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការបំពេញនូវកម្រិតប្រាក់បម្រុងកាតព្វកិច្ច ជាបួនដំណាក់កាល ដែលការទូទាត់លើកចុងក្រោយត្រឹមថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2023។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅមិនទាន់ទទួលបានការឆ្លើយតបពីធនាគារជាតិនៃកម្ពុជានៅឡើយទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 8. សមតុល្យនៅធនាគារផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| គណនីចរន្ត | 2,858,502 | 11,768,453 | 2,240,993 | 9,129,805 |
| គណនីសន្សំ | 147,697 | 608,069 | 90,418 | 368,363 |
| គណនីមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | 3,000,000 | 12,351,000 | - | - |
| សមតុល្យដុលជាមួយធនាគារផ្សេងៗ | 6,006,199 | 24,727,522 | 2,331,411 | 9,498,168 |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (60,062) | (247,276) | (23,314) | (94,981) |
| | 5,946,137 | 24,480,246 | 2,308,097 | 9,403,187 |

គណនីចរន្ត ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំរហូតដល់ 0.75% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.00% ទៅ 0.75%) គណនីសន្សំទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.00% ទៅ 0.50% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.00% ទៅ 0.20%) និងគណនីមានកាលកំណត់ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ 3% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ គ្មាន) ក្នុងអំឡុងការិយបរិច្ឆេទ ។

## 9. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានបុគ្គល | 4,004,309,491 | 226,816,223 | 50,750,343 | 4,281,876,057 | 17,628,483,727 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 61,269,673 | 5,470,637 | 1,131,009 | 67,871,319 | 279,426,220 |
| ឥណទានបុគ្គលិក | 5,716,628 | - | 3,219 | 5,719,847 | 23,548,610 |
| ឥណទានក្រុម | 85,134 | 4,070 | 11,305 | 100,509 | 413,796 |
| | **4,071,380,926** | **232,290,930** | **51,895,876** | **4,355,567,732** | **17,931,872,353** |
| កម្រៃសេវាឥណទានដែលមិនទាន់រំលស់ | (37,763,634) | (1,932,452) | (374,887) | (40,070,973) | (164,972,196) |
| | **4,033,617,292** | **230,358,478** | **51,520,989** | **4,315,496,759** | **17,766,900,157** |
| ការប្រាក់បង្គរ | 30,138,917 | 2,431,552 | 2,017,935 | 34,588,404 | 142,400,459 |
| | **4,063,756,209** | **232,790,030** | **53,538,924** | **4,350,085,163** | **17,909,300,616** |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (12,526,838) | (11,679,826) | (29,756,714) | (53,963,378) | (222,167,227) |
| | **4,051,229,371** | **221,110,204** | **23,782,210** | **4,296,121,785** | **17,687,133,389** |

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានបុគ្គល | 3,265,091,152 | 368,902,868 | 49,638,494 | 3,683,632,514 | 15,007,118,862 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 52,000,845 | 8,839,399 | 1,060,910 | 61,901,154 | 252,185,301 |
| ឥណទានបុគ្គលិក | 7,278,823 | 3,420 | 18,655 | 7,300,898 | 29,743,858 |
| ឥណទានក្រុម | 135,996 | 18,863 | 22,067 | 176,926 | 720,797 |
| | **3,324,506,816** | **377,764,550** | **50,740,126** | **3,753,011,492** | **15,289,768,818** |
| កម្រៃសេវាឥណទានដែលមិនទាន់រំលស់ | (31,195,926) | (3,300,001) | (344,684) | (34,840,611) | (141,940,649) |
| | **3,293,310,890** | **374,464,549** | **50,395,442** | **3,718,170,881** | **15,147,828,169** |
| ការប្រាក់បង្គរ | 24,831,162 | 3,238,478 | 2,117,904 | 30,187,544 | 122,984,054 |
| | **3,318,142,052** | **377,703,027** | **52,513,346** | **3,748,358,425** | **15,270,812,223** |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (8,693,888) | (18,871,562) | (29,224,982) | (56,790,432) | (231,364,220) |
| | **3,309,448,164** | **358,831,465** | **23,288,364** | **3,691,567,993** | **15,039,448,003** |

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ក្នុងអំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន សមតុល្យនៅធនាគារផ្សេងៗ និងទ្រព្យសកម្មផ្សេងៗ ដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានផ្តល់ដល់អតិថិជន | 19,014,983 | 77,714,236 | 14,722,763 | 59,892,200 | 5,875,855 | 24,261,405 | (3,756,066) | (15,294,701) |
| សមតុល្យនៅធនាគារផ្សេងៗ | 36,748 | 150,189 | (16,837) | (68,493) | 29,402 | 121,401 | (32,977) | (134,283) |
| ទ្រព្យសកម្មផ្សេងៗ | 6,783 | 27,722 | 1,933 | 7,863 | 2,740 | 11,314 | 952 | 3,877 |
| | 19,058,514 | 77,892,147 | 14,707,859 | 59,831,570 | 5,907,997 | 24,394,120 | (3,788,091) | (15,425,107) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022**

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

បម្រែបម្រួលសំវិធានធន លើការខាតបង់នៃឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន ក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោមៈ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យនាដើមការិយបរិច្ឆេទ | 56,790,432 | 231,364,220 | 49,613,493 | 200,686,579 | 69,929,560 | 288,039,856 | 68,092,322 | 277,748,581 |
| សំវិធានធន/(តំហាយ)លើការខាតបង់នៃ ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ | 19,014,983 | 77,714,236 | 14,722,763 | 59,892,200 | 5,875,855 | 24,261,405 | (3,756,066) | (15,294,701) |
| ការលុបចេញក្នុងការិយបរិច្ឆេទ | (21,842,037) | (89,268,406) | (7,545,824) | (30,696,412) | (21,842,037) | (90,185,771) | (7,545,824) | (30,726,595) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 2,357,177 | - | 1,481,853 | - | 51,737 | - | (363,065) |
| សមតុល្យនាចុងការិយបរិច្ឆេទ | 53,963,378 | 222,167,227 | 56,790,432 | 231,364,220 | 53,963,378 | 222,167,227 | 56,790,432 | 231,364,220 |

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ការវិភាគបន្ថែមនៃឥណទានផ្តល់ដល់អតិថិជន ត្រូវបានបង្ហាញដូចខាងក្រោមៈ

### (ក) តាមទ្រព្យធានា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| *មានវត្ថុបញ្ចាំ* | | | | |
| អចលនទ្រព្យ (ប្លង់រឹង) | 1,988,387,055 | 8,186,189,505 | 1,649,002,901 | 6,718,037,818 |
| ចលនវត្ថុ | 112,862 | 464,653 | 189,467 | 771,887 |
| ប្រាក់តម្កល់ទុក | 2,596,512 | 10,689,840 | 2,530,818 | 10,310,554 |
| ផ្សេងៗ | 493,240 | 2,030,669 | 640,271 | 2,608,465 |
| *ពុំមានវត្ថុបញ្ចាំ (*)* | | | | |
| អចលនទ្រព្យ (ប្លង់ទន់) | 2,357,520,465 | 9,705,911,754 | 2,094,535,205 | 8,533,136,427 |
| ចលនវត្ថុ | 505,877 | 2,082,696 | 363,670 | 1,481,591 |
| ផ្សេងៗ | 469,152 | 1,931,499 | 1,096,093 | 4,465,481 |
| | 4,350,085,163 | 17,909,300,616 | 3,748,358,425 | 15,270,812,223 |

(*) សំដៅទៅលើកម្ចីដែលវត្ថុបញ្ចាំ រួមមានប្លង់ទន់ និងពុំមានវត្ថុបញ្ចាំ ដែលអ្នកគ្រប់គ្រងជឿថាមានហានិភ័យខ្ពស់ ហើយចាត់ទុកជាកម្ចីពុំមានវត្ថុបញ្ចាំ។

### (ខ) តាមនិវាសនភាព ទំនាក់ទំនងរូបិយប័ណ្ណ និងតាមវិស័យនានា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ***និវាសនភាព*** | | | | |
| និវាសនជន | 4,350,085,163 | 17,909,300,616 | 3,748,358,425 | 15,270,812,223 |
| ***ទំនាក់ទំនង*** | | | | |
| អតិថិជនខាងក្រៅ | 4,344,363,930 | 17,885,746,300 | 3,741,058,685 | 15,241,073,082 |
| ឥណទានបុគ្គលិក | 5,721,233 | 23,554,316 | 7,299,740 | 29,739,141 |
| | 4,350,085,163 | 17,909,300,616 | 3,748,358,425 | 15,270,812,223 |

## 9. ឥណទានផ្ដល់ដល់អតិថិជន (ត)

### (ខ) តាមនិវាសនភាព ទំនាក់ទំនងរូបិយប័ណ្ណ និងតាមវិស័យនានា (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| *រូបិយប័ណ្ណ* | | | | |
| ដុល្លារអាមេរិក | 3,807,388,176 | 15,675,017,121 | 3,286,440,759 | 13,388,959,652 |
| រៀលខ្មែរ | 539,305,197 | 2,220,319,496 | 452,563,732 | 1,843,744,644 |
| បាតថៃ | 3,391,790 | 13,963,999 | 9,353,934 | 38,107,927 |
| | 4,350,085,163 | 17,909,300,616 | 3,748,358,425 | 15,270,812,223 |
| *វិស័យ* | | | | |
| ពាណិជ្ជកម្ម និងជំនួញ | 1,168,443,276 | 4,810,480,967 | 1,006,083,731 | 4,098,785,121 |
| សេវាកម្ម | 715,963,592 | 2,947,622,108 | 650,895,034 | 2,651,746,369 |
| អចលនទ្រព្យ | 666,094,479 | 2,742,310,970 | 536,199,895 | 2,184,478,372 |
| កែលម្អគេហដ្ឋាន | 580,109,380 | 2,388,310,317 | 453,670,525 | 1,848,253,719 |
| កសិកម្ម | 514,068,358 | 2,116,419,430 | 445,927,277 | 1,816,707,726 |
| យានយន្ត | 327,666,923 | 1,349,004,722 | 299,573,327 | 1,220,461,734 |
| ការដឹកជញ្ជូន | 253,111,335 | 1,042,059,366 | 249,173,560 | 1,015,133,083 |
| ផលិតកម្ម | 48,430,882 | 199,389,941 | 45,502,628 | 185,377,706 |
| សំណង់ | 47,556,510 | 195,790,152 | 39,316,458 | 160,175,250 |
| ប្រើប្រាស់ផ្ទាល់ខ្លួន | 28,640,428 | 117,912,643 | 22,015,990 | 89,693,143 |
| | 4,350,085,163 | 17,909,300,616 | 3,748,358,425 | 15,270,812,223 |

## 10. ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ប្រាក់បង់មុន | 3,413,531 | 14,053,507 | 1,188,294 | 4,841,110 |
| ប្រាក់កក់ | 950,824 | 3,914,542 | 611,637 | 2,491,809 |
| ការវិនិយោគរយៈពេលវែង | 28,167 | 115,964 | 28,167 | 114,752 |
| ផ្សេងៗ | 802 | 3,302 | 104 | 424 |
| | 4,393,324 | 18,087,315 | 1,828,202 | 7,448,095 |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (19,016) | (78,289) | (12,233) | (49,837) |
| | 4,374,308 | 18,009,026 | 1,815,969 | 7,398,258 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022**

## 11. ទ្រព្យ និងបរិក្ខារ

សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | គ្រឿងសង្ហារឹម | យានយន្ត | ទោចក្រយានយន្ត | កុំព្យូទ័រ និង បរិក្ខារបច្ចេកវិទ្យា | ការកែលម្អអគារ | បរិក្ខារ ទំនាក់ទំនង | ទ្រព្យកំពុង បង្កើត | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 5,517,131 | 2,851,723 | 360,678 | 9,797,701 | 2,419,207 | 344,072 | 288,696 | 21,579,208 | 87,913,693 |
| ការទិញបន្ថែម | 453,373 | 308,500 | - | 475,794 | 23,570 | 3,277 | 778,179 | 2,042,693 | 8,348,486 |
| ការលក់ចេញ ឬលុបចេញ | (131,500) | (240,500) | - | (529,968) | (73,230) | (924) | - | (976,122) | (3,989,411) |
| ការផ្ទេរ | 203,960 | - | - | 763,003 | 46,309 | - | (1,013,272) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | 959,904 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 6,042,964 | 2,919,723 | 360,678 | 10,506,530 | 2,415,856 | 346,425 | 53,603 | 22,645,779 | 93,232,672 |
| ដកៈ **រំលស់បង្គរ** | | | | | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 4,582,179 | 2,313,720 | 353,407 | 7,235,877 | 1,952,147 | 280,360 | - | 16,717,690 | 68,107,868 |
| រំលស់ក្នុងការិយបរិច្ឆេទ | 380,665 | 270,708 | 3,588 | 1,278,298 | 141,300 | 31,464 | - | 2,106,023 | 8,607,316 |
| ការលក់ចេញ ឬលុបចេញ | (130,619) | (240,500) | - | (519,923) | (72,703) | (924) | - | (964,669) | (3,942,602) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | 753,102 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 4,832,225 | 2,343,928 | 356,995 | 7,994,252 | 2,020,744 | 310,900 | - | 17,859,044 | 73,525,684 |
| **តម្លៃយោង** | | | | | | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 1,210,739 | 575,795 | 3,683 | 2,512,278 | 395,112 | 35,525 | 53,603 | 4,786,735 | 19,706,988 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 11. ទ្រព្យ និងបរិក្ខារ (ត)

សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

| | គ្រឿងសង្ហារឹម | យានយន្ត | ទោចក្រយានយន្ត | កុំព្យូទ័រ និងបរិក្ខារបច្ចេកវិទ្យា | ការកែលម្អអគារ | បរិក្ខារទំនាក់ទំនង | ទ្រព្យកំពុងបង្កើត | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 5,355,637 | 3,037,394 | 360,678 | 9,030,420 | 2,401,455 | 326,356 | 295,714 | 20,807,654 | 84,166,960 |
| ការទិញបន្ថែម | 190,187 | 97,500 | - | 365,373 | 5,674 | 17,716 | 605,922 | 1,282,372 | 5,216,689 |
| ការលក់ចេញ ឬលុបចេញ | (55,778) | (283,171) | - | (165,606) | (6,263) | - | - | (510,818) | (2,078,008) |
| ការផ្ទេរ | 27,085 | - | - | 567,514 | 18,341 | - | (612,940) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | 608,052 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 5,517,131 | 2,851,723 | 360,678 | 9,797,701 | 2,419,207 | 344,072 | 288,696 | 21,579,208 | 87,913,693 |
| **ដកៈ រំលស់បង្គរ** | | | | | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 4,222,332 | 2,315,084 | 349,819 | 6,215,744 | 1,788,910 | 252,962 | - | 15,144,851 | 61,260,921 |
| រំលស់ក្នុងការិយបរិច្ឆេទ | 413,709 | 273,348 | 3,588 | 1,184,888 | 169,500 | 27,398 | - | 2,072,431 | 8,430,649 |
| ការលក់ចេញ ឬលុបចេញ | (53,862) | (274,712) | - | (164,755) | (6,263) | - | - | (499,592) | (2,032,340) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | 448,638 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 4,582,179 | 2,313,720 | 353,407 | 7,235,877 | 1,952,147 | 280,360 | - | 16,717,690 | 68,107,868 |
| **តម្លៃយោង** | | | | | | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 934,952 | 538,003 | 7,271 | 2,561,824 | 467,060 | 63,712 | 288,696 | 4,861,518 | 19,805,825 |

## 12. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុនបានជួលទីតាំងការិយាល័យ សម្រាប់ជាការិយាល័យកណ្តាល និងសាខា ព្រមទាំងទីតាំងដាក់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ។ ព័ត៌មានអំពីភតិសន្យាដែលក្រុមហ៊ុនជាអ្នកភតិក: ត្រូវបានបង្ហាញដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | | |
|---|---|---|---|---|
| | ការិយាល័យ | ទីតាំង ATM | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 30,328,390 | 811,909 | 31,140,299 | 126,865,578 |
| ការបន្ថែម | 6,458,024 | 313,816 | 6,771,840 | 27,676,510 |
| ការបញ្ឈប់មុនកាលកំណត់ | (41,539) | - | (41,539) | (169,770) |
| ការផុតកាលកំណត់ | (3,146,559) | (448,088) | (3,594,647) | (14,691,322) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 1,433,103 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 33,598,316 | 677,637 | 34,275,953 | 141,114,099 |
| ដក៖ **រំលស់បង្គរ** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 14,414,971 | 627,685 | 15,042,656 | 61,283,780 |
| រំលស់ក្នុងការិយបរិច្ឆេទ | 4,202,112 | 181,825 | 4,383,937 | 17,917,151 |
| ការបញ្ឈប់មុនកាលកំណត់ | (39,303) | - | (39,303) | (160,630) |
| ការផុតកាលកំណត់ | (3,146,559) | (448,088) | (3,594,647) | (14,691,322) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 669,333 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 15,431,221 | 361,422 | 15,792,643 | 65,018,312 |
| **តម្លៃយោង** | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 18,167,095 | 316,215 | 18,483,310 | 76,095,787 |

## 12. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម (ត)

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | |
|---|---|---|---|---|
| | ការិយាល័យ | ទីតាំងATM | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 25,638,528 | 717,053 | 26,355,581 | 106,608,325 |
| ការបន្ថែម | 4,689,862 | 94,856 | 4,784,718 | 19,464,233 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 793,020 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 30,328,390 | 811,909 | 31,140,299 | 126,865,578 |
| **ដកៈរំលស់បង្គរ** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 10,579,042 | 454,360 | 11,033,402 | 44,630,111 |
| រំលស់ក្នុងការិយបរិច្ឆេទ | 3,835,929 | 173,325 | 4,009,254 | 16,309,647 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 344,022 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 14,414,971 | 627,685 | 15,042,656 | 61,283,780 |
| **តម្លៃយោង** | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 15,913,419 | 184,224 | 16,097,643 | 65,581,798 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 13. ទ្រព្យសកម្មអរូបី

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | | | |
|---|---|---|---|---|---|
| | កុំព្យូទ័រ សូហ្វវែរ | ប្រព័ន្ធស្នូល ធនាគារ | ទ្រព្យកំពុង បង្កើត | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 1,264,054 | 2,891,587 | - | 4,155,641 | 16,930,081 |
| ការទិញបន្ថែម | - | - | 16,800 | 16,800 | 68,662 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | 179,197 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 1,264,054 | 2,891,587 | 16,800 | 4,172,441 | 17,177,940 |
| ដកៈ **រំលស់បង្គរ** | | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 925,837 | 1,875,275 | - | 2,801,112 | 11,411,732 |
| រំលស់ក្នុងការិយបរិច្ឆេទ | 103,650 | 188,352 | - | 292,002 | 1,193,412 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | 129,207 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 1,029,487 | 2,063,627 | - | 3,093,114 | 12,734,351 |
| **តម្លៃយោង** | | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 234,567 | 827,960 | 16,800 | 1,079,327 | 4,443,589 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 13. ទ្រព្យសកម្មអរូបី (ត)

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | |
|---|---|---|---|---|
| | កុំព្យូទ័រ សូហ្វវែរ | ប្រព័ន្ធស្នូល ធនាគារ | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 1,220,319 | 2,891,587 | 4,111,906 | 16,632,661 |
| ការទិញបន្ថែម | 43,735 | - | 43,735 | 177,914 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 119,506 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 1,264,054 | 2,891,587 | 4,155,641 | 16,930,081 |
| ដកៈ **រំលស់បង្គរ** | | | | |
| សមតុល្យនាដើមការិយបរិច្ឆេទ | 817,815 | 1,686,923 | 2,504,738 | 10,131,666 |
| រំលស់ក្នុងការិយបរិច្ឆេទ | 108,022 | 188,352 | 296,374 | 1,205,648 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 74,416 |
| សមតុល្យនាចុងការិយបរិច្ឆេទ | 925,837 | 1,875,275 | 2,801,112 | 11,411,730 |
| **តម្លៃយោង** | | | | |
| សមតុល្យនាចុងការិយបរិច្ឆេទ | 338,217 | 1,016,312 | 1,354,529 | 5,518,351 |

### 14. ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ប្រាក់បញ្ញើមានកាលកំណត់ | 49,856,431 | 205,258,927 | 77,619,435 | 316,221,578 |
| ប្រាក់បញ្ញើសន្សំ | 180,687 | 743,888 | 4,262,143 | 17,363,971 |
| | 50,037,118 | 206,002,815 | 81,881,578 | 333,585,549 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 14. ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ (ត)

ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗត្រូវបានវិភាគដូចខាងក្រោមៈ

### (ក) តាមសម្ព័ន្ធញាតិ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| មិនមែនសម្ព័ន្ធញាតិ | 27,277,134 | 112,299,961 | 62,727,192 | 255,550,580 |
| សម្ព័ន្ធញាតិ | 22,759,984 | 93,702,854 | 19,154,386 | 78,034,969 |
| | 50,037,118 | 206,002,815 | 81,881,578 | 333,585,549 |

### (ខ) តាមអត្រាការប្រាក់ប្រចាំឆ្នាំ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | | |
| ដុល្លារអាមេរិក | 3.00% - 6.50% | 2.00% - 5.25% |
| រៀលខ្មែរ | គ្មាន | គ្មាន |
| ប្រាក់បញ្ញើសន្សំ | | |
| ដុល្លារអាមេរិក | 0.00% | 0.00% |
| រៀលខ្មែរ | 0.00% | 0.00% |

## 15. ប្រាក់បញ្ញើរបស់អតិថិជន

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ប្រាក់បញ្ញើមានកាលកំណត់ | 2,576,555,725 | 10,607,679,920 | 2,397,228,295 | 9,766,308,074 |
| ប្រាក់បញ្ញើសន្សំ | 150,652,137 | 620,234,848 | 136,102,560 | 554,481,829 |
| | 2,727,207,862 | 11,227,914,768 | 2,533,330,855 | 10,320,789,903 |

## 15. ប្រាក់បញ្ញើរបស់អតិថិជន (ត)

ប្រាក់បញ្ញើរបស់អតិថិជនត្រូវបានវិភាគដូចខាងក្រោមៈ

### (ក) តាមសម្ព័ន្ធញាតិ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| មិនមែនសម្ព័ន្ធញាតិ | 2,710,332,854 | 11,158,440,360 | 2,481,756,245 | 10,110,674,942 |
| សម្ព័ន្ធញាតិ | 16,875,008 | 69,474,408 | 51,574,610 | 210,114,961 |
| | 2,727,207,862 | 11,227,914,768 | 2,533,330,855 | 10,320,789,903 |

### (ខ) តាមអត្រាការប្រាក់ប្រចាំឆ្នាំ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | | |
| ដុល្លារអាមេរិក | 2.75% - 8.50% | 0.75% - 8.25% |
| រៀលខ្មែរ | 2.00% - 10.15% | 2.00% - 10.15% |
| បាតថៃ | 0.10% - 7.25% | 0.10% - 8.00% |
| ប្រាក់បញ្ញើសន្សំ | | |
| ដុល្លារអាមេរិក | 0.00% - 3.00% | 0.00% - 3.00% |
| រៀលខ្មែរ | 0.00% - 3.00% | 0.00% - 3.00% |
| បាតថៃ | 0.00% - 0.10% | 0.00% - 0.10% |

## 16. ប្រាក់កម្ចី

ក្រុមហ៊ុន បានចុះកិច្ចព្រមព្រៀងខ្ចីប្រាក់ជាមួយអ្នកផ្តល់ប្រាក់កម្ចីផ្សេងៗរួមមានសម្ព័ន្ធញាតិ និងមិនមែនសម្ព័ន្ធញាតិ។ ប្រាក់កម្ចីទាំងនេះពុំមានវត្ថុបញ្ចាំនោះឡើយ ហើយការទូទាត់សងប្រាក់ដើម និងការប្រាក់ត្រូវធ្វើឡើងប្រចាំត្រីមាស ឆមាស ឬប្រចាំឆ្នាំ ដោយផ្អែកតាមកាលវិភាគទូទាត់សង នៃកិច្ចព្រមព្រៀងខ្ចីនីមួយៗ។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមិនបានបំពេញបាននៅលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌប្រាក់កម្ចីផ្សេងៗ ចំពោះប្រាក់កម្ចីមួយដែលមានទឹកប្រាក់យោងចំនួន 17,142,857ដុល្លារអាមេរិក និងចំពោះកិច្ចព្រមព្រៀងធានាលើមូលបត្របំណុលសម្រាប់ការធានាលើមូលបត្របំណុលត្រូវសងរបស់ខ្លួន។ នៅក្នុងកិច្ចព្រមព្រៀងបានចែងថា នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ មូលនិធិមានស្ថេរភាពដែលអាចប្រើប្រាស់បានរបស់ក្រុមហ៊ុន មិនអាចទាបជាង 85% នៃមូលនិធិមានស្ថេរភាពតាមតម្រូវការ នោះទេ បើមិនដូច្នេះទេ ប្រាក់កម្ចីនឹងត្រូវបង់តាមតម្រូវការ។ ក៏ប៉ុន្តែ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 មូលនិធិមានស្ថេរភាពដែលអាចប្រើប្រាស់បានរបស់ក្រុមហ៊ុន មានត្រឹមតែ 83.63% នៃមូលនិធិមានស្ថេរភាពតាមតម្រូវការតែប៉ុណ្ណោះ។

ក្រុមហ៊ុនបានទទួលអ៊ីម៉ែល នៅថ្ងៃទី8 ខែកុម្ភៈ ឆ្នាំ2023 និងថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2023 ពីអ្នកធានា និងម្ចាស់បំណុលរៀងគ្នា លើការអនុម័តកែប្រែលើលក្ខខណ្ឌខាងលើពី 85% មកត្រឹម80% សម្រាប់ការិយបរិច្ឆេទនៃរបាយការណ៍នេះ រហូតដល់ថ្ងៃទី31 ខែមីនា ឆ្នាំ2023។ ដោយផ្អែកតាមមូលដ្ឋាននៃ លក្ខខណ្ឌថ្មីនេះ រួមនឹងការព្យាករណ៍របស់ក្រុមហ៊ុន អ្នកគ្រប់គ្រងជឿថា មិនមានហានិភ័យដែលលក្ខខណ្ឌថ្មីនេះ មិនអាចបំពេញបាននោះទេ។ ក្រុមហ៊ុនកំពុងស្ថិតនៅក្នុងដំណើរការស្នើសុំលិខិតលើកលែងលក្ខខណ្ឌប្រាក់កម្ចីជាផ្លូវការ ដោយយោងតាមអ៊ីម៉ែលខាងលើ។

ប្រាក់កម្ចី ត្រូវបានវិភាគដូចខាងក្រោម៖

### (ក) តាមសម្ព័ន្ធញាតិ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| មិនមែនសម្ព័ន្ធញាតិ | 689,092,420 | 2,836,993,493 | 715,840,327 | 2,916,333,492 |
| សម្ព័ន្ធញាតិ | 282,167,005 | 1,161,681,560 | 113,981,537 | 464,360,782 |
| | 971,259,425 | 3,998,675,053 | 829,821,864 | 3,380,694,274 |

## 16. ប្រាក់កម្ចី (ត)

ប្រាក់កម្ចី ត្រូវបានវិភាគដូចខាងក្រោម៖

### (ខ) តាមអត្រាការប្រាក់ប្រចាំឆ្នាំ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| ដុល្លារអាមេរិក | 2.00% - 10.21% | 2.00% - 6.98% |
| រៀលខ្មែរ | 2.00% - 7.40% | 2.00% - 7.50% |
| បាតថៃ | គ្មាន | 8.37% - 8.84% |

## 17. មូលបត្របំណុលត្រូវសង

នៅខែមេសា ឆ្នាំ2020 ក្រុមហ៊ុនបានបោះផ្សាយមូលបត្របំណុលមានការធានា ដែលមានអត្រាការប្រាក់ថេរ ចំនួន 127.2 ប៊ីលានរៀល (សមមូលទៅនឹង 31.17 លានដុល្លារអាមេរិក) ដែលមានកាលវសាននៅថ្ងៃទី23 ខែមេសា ឆ្នាំ2023។ មូលបត្របំណុលត្រូវបានធានាដោយការធានាឥណទាន និងហ្វាស៊ីលីធីវិនិយោគ ដែលជាមូលនិធិបរធនបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ មូលបត្របំណុលត្រូវបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា ហើយត្រូវបានលក់ក្នុងតម្លៃ 100,000 រៀលក្នុង 1 មូលបត្រ ដោយមានអត្រាការប្រាក់ 7.50% ក្នុងមួយឆ្នាំ និងត្រូវសងត្រឡប់ 2ដង ក្នុងមួយឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី23 ខែតុលា ឆ្នាំ2020។ ក្រុមហ៊ុនបានចំណាយលើថ្លៃបោះផ្សាយមូលបត្របំណុលចំនួន 6.21 ប៊ីលានរៀល (សមមូលទៅនឹង 1.52 លានដុល្លារអាមេរិក)។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 តម្លៃយោងនៃមូលបត្របំណុល មានចំនួន 31,168,428 ដុល្លារអាមេរិក (សមមូលទៅនឹង 128.32 ប៊ីលានរៀល) (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 31,342,099 ដុល្លារអាមេរិក សមមូលទៅនឹង 127.69 ប៊ីលានរៀល)។ ក្នុងអំឡុងដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមានចំណាយលើការប្រាក់លើមូលបត្របំណុលដែលបានបោះផ្សាយ ចំនួន 2,510,158 ដុល្លារអាមេរិក (សមមូលទៅនឹង 10.26 ប៊ីលានរៀល) (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 2,601,274 ដុល្លារអាមេរិក ដែលសមមូលទៅនឹង 10.58 ប៊ីលានរៀល) (កំណត់សម្គាល់ 25)។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 18. អនុបំណុល

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| អនុបំណុល | 89,677,427 | 369,201,967 | 105,191,790 | 428,551,352 |

អនុបំណុល សំដៅលើបំណុលខ្ចីពីម្ចាស់បំណុលបរទេស (ដែលមិនមែនជាសម្ព័ន្ធញាតិ) ដែលមានចំនួនទឹកប្រាក់ 39,402,454 ដុល្លារអាមេរិក (សមមូលទៅនឹង 162.22 ប៊ីលានរៀល) (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 54,999,653 ដុល្លារអាមេរិក ដែលសមមូលទៅនឹង 224.1 ប៊ីលានរៀល) និងពីម្ចាស់ភាគហ៊ុនមានចំនួន 50,274,973 ដុល្លារអាមេរិក (សមមូលទៅនឹង 206.98 ប៊ីលានរៀល) (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 50,192,137 ដុល្លារអាមេរិក ដែលសមមូលទៅនឹង 204.5 ប៊ីលានរៀល) ត្រូវទូទាត់ដោយផ្អែកទៅតាមកាលវិភាគទូទាត់សងប្រាក់ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងកម្ចីនីមួយៗ។ អនុបំណុល ពីម្ចាស់ភាគហ៊ុនត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ឲ្យដាក់បញ្ចូលទៅក្នុងដើមទុនថ្នាក់ទី2 សម្រាប់ការគណនាមូលនិធិផ្ទាល់សុទ្ធ។ អត្រាការប្រាក់ប្រចាំឆ្នាំមានចាប់ពី 6.98% ទៅ 10.47% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចាប់ពី 6.98% ដល់ 10.47%) ក្នុងអំឡុងការិយបរិច្ឆេទ។

## 19. បំណុលភតិសន្យា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ការវិភាគតាមកាលកំណត់-លំហូរទឹកប្រាក់តាមកិច្ចសន្យាមិនទាន់ធ្វើអប្បហារ** | | | | |
| តិចជាង 1ឆ្នាំ | 5,293,989 | 21,795,353 | 4,494,357 | 18,310,009 |
| ពី 1 ទៅ 5ឆ្នាំ | 13,801,905 | 56,822,442 | 11,814,043 | 48,130,411 |
| ច្រើនជាង 5ឆ្នាំ | 4,326,301 | 17,811,381 | 2,713,396 | 11,054,377 |
| **បំណុលភតិសន្យាសរុបមិនទាន់ធ្វើអប្បហារ** | 23,422,195 | 96,429,176 | 19,021,796 | 77,494,797 |
| **តម្លៃបច្ចុប្បន្ននៃបំណុលភតិសន្យា** | | | | |
| រយៈពេលខ្លី | 3,998,954 | 16,463,692 | 3,407,054 | 13,880,338 |
| រយៈពេលវែង | 14,974,273 | 61,649,084 | 12,184,384 | 49,639,180 |
| | 18,973,227 | 78,112,776 | 15,591,438 | 63,519,518 |

## 19. បំណុលភតិសន្យា (ត)

ចំនួនដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតៈ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យារយៈពេលខ្លី និងទ្រព្យសកម្មដែលមានតម្លៃទាប | 726,076 | 2,967,473 | 815,242 | 3,316,404 | 138,635 | 572,424 | 226,265 | 921,351 |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | 1,898,088 | 7,757,486 | 1,703,815 | 6,931,119 | 284,803 | 1,175,952 | 905,865 | 3,688,682 |
| | 2,624,164 | 10,724,959 | 2,519,057 | 10,247,523 | 423,438 | 1,748,376 | 1,132,130 | 4,610,033 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 19. បំណុលភតិសន្យា (ត)

ចំនួនដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សរុបលំហូរចេញនៃទឹកប្រាក់លើភតិសន្យា៖ | | | | |
| ចំណែកប្រាក់ដើម | (3,973,113) | (16,238,113) | (3,618,098) | (14,718,423) |
| ចំណែកការប្រាក់ | (1,325,325) | (5,416,603) | (1,703,815) | (6,931,119) |
| | (5,298,438) | (21,654,716) | (5,321,913) | (21,649,542) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 20. ពន្ធលើប្រាក់ចំណេញ

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន នឹងត្រូវបានត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ ("អ.ព.ដ")។ ដោយសារការអនុវត្តច្បាប់ និងបទបញ្ញត្តិសារពើពន្ធលើប្រភេទប្រតិបត្តិការជាច្រើន មានការបកស្រាយផ្សេងៗគ្នា ដូច្នេះចំនួនដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល អាចនឹងកែប្រែនៅពេលក្រោយបន្ទាប់ពីការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

### (ក) ចំណាយពន្ធលើប្រាក់ចំណេញ

*អត្រាពន្ធផ្លូវការ*

អនុលោមតាមបទប្បញ្ញត្តិពន្ធដារកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញនូវអត្រាពន្ធ 20% នៃចំណូលជាប់ពន្ធ ឬពន្ធអប្បបរមា 1% នៃផលរបរដោយរួមបញ្ចូលពន្ធទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម ទៅតាមចំនួនមួយណាដែលច្រើនជាង។

យោងទៅតាមអនុក្រឹត្យស្តីពីការអនុគ្រោះពន្ធនៅក្នុងទីផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមានសិទ្ធិទទួលបាននូវការកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួនពាក់កណ្តាលនៅក្នុងអំឡុងពេលនៃការអនុគ្រោះពន្ធ។ ដើម្បីទទួលបានការអនុគ្រោះពន្ធនេះ ក្រុមហ៊ុនត្រូវស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ តាមរយៈនិយ័តករមូលបត្រកម្ពុជា ("ន.ម.ក") (ពីមុនត្រូវបានស្គាល់ជាគណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក") រហូតដល់ថ្ងៃទី8 ខែមេសា ឆ្នាំ2021) មុនពេលបញ្ចប់នៃឆ្នាំសារពើពន្ធនីមួយៗ។

នៅថ្ងៃទី4 ខែកុម្ភៈ ឆ្នាំ2021 ក្រុមហ៊ុនទទួលបានលិខិតពីនិយ័តករមូលបត្រកម្ពុជា ដែលបញ្ជាក់ពីការស្នើសុំរបស់ក្រុមហ៊ុនលើការអនុគ្រោះពន្ធទៅកាន់អគ្គនាយកដ្ឋានពន្ធដារ។ ក្រុមហ៊ុនបានដាក់លិខិតស្នើសុំការបញ្ជាក់បន្ថែម ទៅកាន់អគ្គនាយកដ្ឋានពន្ធដារ ទាក់ទងនឹងការអនុម័តលើការអនុគ្រោះពន្ធនេះ។ នៅថ្ងៃទី11 ខែមីនា ឆ្នាំ2021 ក្រុមហ៊ុនទទួលបានការអនុម័តពីអគ្គនាយកដ្ឋានពន្ធដារលើការអនុគ្រោះពន្ធ សម្រាប់ឆ្នាំសារពើពន្ធ 2020 និង2021 ទៅតាមប្រកាសថ្មីលេខ 183 ចុះថ្ងៃទី25 ខែមករា ឆ្នាំ2020 ស្តីពីគោលការណ៍អនុវត្តពីការអនុគ្រោះពន្ធលើប្រាក់ចំណេញ ចំពោះសហគ្រាសដែលបោះផ្សាយមូលបត្រដំបូង។

